# ខ្លឹមធម៌របស់ព្រះពុទ្ធសាសនា

## THE CORE TEACHINGS OF BUDDHISM

ការសិក្សាទៅលើខ្លឹមធម៌របស់ព្រះពុទ្ធសាសនា ជាបញ្ហាមួយសំខាន់និងចាំបាច់ដែរសំរាប់ពុទ្ធបរិស័ទ ដែលត្រូវយល់ឱ្យច្បាស់មុននឹងយកទៅបដិបត្តិឬផ្សព្វផ្សាយបន្ត ។ម្យ៉ាងទៀតការជជែកវែកញែកទៅលើខ្លឹមធម៌ខ្លាំងពេកក៏នាំឱ្យយើងមាន**វិចិកិច្ឆា** (ការសង្ស័យ) ដែលជាឧបសគ្គ (**នីវរណ៍**)មួយនៃការបដិបត្តិឬក៏អាចមានការបែងចែកជាក្រុមជាពួក ហើយម្នាក់ៗអាចប្រកាន់ខ្ជាប់ថា មានតែទ្រឹស្តីរបស់ពួកខ្លួន ក្រុមខ្លួនប៉ុណ្ណោះដែលជាពាក្យប្រៀនប្រដៅពិត ឬជាខ្លឹមធម៌របស់ព្រះពុទ្ធសាសនា ។ ការប្រកាន់ជ្រុលទាំងនេះអាចជាផលអាក្រក់ចំពោះព្រះពុទ្ធសាសនា និងជាកាផ្ទុយស្រឡះចំពោះព្រះពុទ្ធវចនៈដែលថា "***សព្វេ ធម្មា នាលំ អភិនិវេសាយៈ***" ដែលមានន័យថា "*ធម៌ទាំងឡាយទាំងពួងមិនឱ្យយើងចូលទៅជាប់ជំពាក់ឬប្រកាន់ជ្រុល*" ។

តែជាធម្មតានៅពេលដែលនិយាយអំពីខ្លឹមធម៌ពិតរបស់ព្រះពុទ្ធសាសនា ជៀសមិនរួចពីការលើកមកលាតត្រដាងខ្លះ នូវចំណុចសំខាន់ៗ ហើយធ្លាប់មានពុទ្ធបរិស័ទយកទៅជជែកពិភាក្សាដេញដោលគ្នាជាញឹកញយ ។ តាមការពិតព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងសុទ្ធសឹងតែមានភាពសំខាន់អាស្រ័យទាក់ទងគ្នាទាំងអស់ គឺប្រៀបបានជាអាវស្អាតដែលកើតអំពីសរសៃអំបោះសូត្រជាច្រើនសរសៃចាក់ស្រេះបញ្ចូលគ្នា ។

អ្នកខ្លះនិយាយថា ខ្លឹមធម៌សំខាន់របស់ព្រះពុទ្ធអង្គគឺនៅត្រង់ព្រះអង្គឱ្យ*ឱវាទបដិមោក្ខ*[1] ដែលមានន័យដោយសព្ទថា "ពាក្យប្រៀនប្រដៅជាធំឬសំខាន់" ដែលពេលនោះព្រះអង្គសំដែងក្នុងថ្ងៃ ១៥កើត ខែមាឃ ឬ ពុទ្ធបរិស័ទយើងហៅថាចតុរង្គសន្និបាត (ប្រែថាការប្រជុំប្រកបដោយអង្គ៤) ។ នៅក្នុងមហាបទានសូត្រទីឃនិកាយ ព្រះអង្គសំដែងឃ្លានេះមុនគេថា :

**ខន្តី បរមំ តបោ តីតិក្ខា  និព្វានំ បរមំ វទន្តិ ពុទ្ធា**

**ន ហិ បព្វជិតោ បរូបឃាតី  សមណោ ហោតិ បរំ វិហេឋយន្តោ ឞ**

ដែលអាចប្រែនិងអធិប្បាយបានខ្លះថា *ខន្តី បរមំ តបោ តីតិក្ខា* ប្រែថា "ខន្តីគឺការអត់ធន់ជាតបៈដ៏ឧត្តម" នេះបញ្ជាក់នូវខ្លឹមធម៌នៃពាក្យប្រៀនប្រដៅដំបូងមួយរបស់ព្រះអង្គ ដែលប្រកាសឡើងផ្ទុយស្រលះពីលទ្ធិមុនៗមានដូចជាសាសនាព្រាហ្មណ៍ជាដើម ។ សាសនាព្រាហ្មណ៍ឬលទ្ធិផ្សេងៗពេលនោះឬមុននោះជឿថា សេចក្តីរួចចាកទុក្ខ ឬការបានប្រោសប្រទានពរពីព្រះជាម្ចាស់ គឺបានតាមរយៈការធ្វើតបៈ ការធ្វើបាប

[1] The Principle Teaching; the Fundamental Teaching; exhortatory Paatimokkha or The Fundamental Precepts; the fundamental rules of the Order; the 227 disciplinary rules binding on Bhikkhus; a collection of the fundamental precepts of the Order recited every fortnight.

ខ្លួនឯង មានដូចជាការអត់អាហារ ការឈរជើងមួយរាប់ម៉ោង ការកប់ខ្លួនឯងក្នុងដីឱ្យនៅតែរន្ធច្រមុះ ការអត់ដង្ហើមខ្យល់ចេញចូល ការហាលកំដៅថ្ងៃ ជាដើម។ ចំណែកសាសនាជេនវិញ មានពីរនិកាយគឺនិកាយ *ស្វេតាម្ពរៈ*គឺស្លៀកដណ្ដប់ពណ៌ស មានការហ៊ុមច្រមុះ ហ៊ុមមាត់ ឬត្រងទឹកម្ដងហើយម្ដងទៀតមុននឹងផឹក ដើម្បីកុំឱ្យសត្វល្អិតចូល។ និកាយមួយទៀតគឺ*ទិគម្ពរៈ*ដែលមានន័យថា "ស្លៀកពាក់គ្របដណ្ដប់ទិស" គឺមានន័យថាស្លៀកខ្យល់ដណ្ដប់មេឃនោះឯង។ ពួកទីពីរនេះគឺគ្មានសំលៀកបំពាក់ទេ ធ្វើការលត់ដំខ្លួនឯងយ៉ាងទំងន់ ទ្រាំទ្រដល់អាកាសក្ដៅត្រជាក់ និងទប់ស្កាត់អង្គជាតិកុំឱ្យកំរើកញាប់ញ័របាន។ តែធម៌របស់ព្រះសម្មាសម្ពុទ្ធគឺត្រាស់ថា "តបៈគឺខន្តី" ដែលមានន័យថាអត់ធន់ចំពោះការងារ អត់ធន់ចំពោះពាក្យសំដី អត់ធន់ចំពោះការធ្វើសេចក្ដីល្អ និងអត់ធន់ចំពោះការបដិបត្តិធម៌ រហូតដល់បានសំរេចព្រះនិព្វានជាទីបំផុត។ មួយទៀតគឺ *និព្វានំ បរមំ វទន្តិ ពុទ្ធា* ដែលប្រែថា "ព្រះពុទ្ធជាម្ចាស់ទាំងឡាយត្រាស់ថាព្រះនិព្វានជាបរមធម៌"។ នេះបញ្ជាក់កាន់តែច្បាស់ទៅទៀត តាមពាក្យថាព្រះពុទ្ធជាម្ចាស់ទាំងឡាយ និង ព្រះនិព្វានជាបរមធម៌។ កាលដើមឡើយសាសនាទាំងឡាយរកមិនឃើញព្រះនិព្វានទេ រកឃើញត្រឹមតែ **ព្រហ្មសហព្យតា** ដែលជាសភាវៈខ្ពស់បំផុតពេលមនុស្សត្រូវបានរលាយចូលជាមួយព្រះព្រហ្ម។ ក្នុងនោះនៅក្នុង*តេវិជ្ជសូត្រ* ព្រះត្រៃបិដក ទីឃនិកាយ ដែលមានការជជែកដេញដោលគ្នាអំពីការរលាយចូលជាមួយព្រហ្មនោះ រលាយចូលយ៉ាងណា?។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា ការរលាយចូលជាមួយព្រហ្មបាននោះគឺត្រូវបដិបត្តិឬចំរើនតាម*ព្រហ្មវិហារធម៌*[2]។ តែធ្វើដូច្នេះគឺបានសំរេចត្រឹមតែឋានព្រហ្ម មិនអាចទៅកាន់ព្រះនិព្វានបានឡើយ។ ចំណែកសាសនាធំៗក្នុងបច្ចុប្បន្ននេះ ដែលមានច្រើនបែបច្រើនយ៉ាង ជាពិសេសសាសនាធំៗ មានដូចជាសាសនាគ្រិស្តនិងសាសនាអ៊ីស្លាម ដែលសង្កត់ធ្ងន់ទៅលើការជឿព្រះ តើព្រះនោះគឺព្រះអ្វី? ព្រះពុទ្ធ ព្រះធម៌ ព្រះព្រហ្ម ព្រះយេហូវ៉ា ព្រះអាឡា ឬក៏ព្រះនិព្វាន។ បើព្រះពុទ្ធ ព្រះអង្គត្រាស់ថាចំរើនព្រហ្មវិហារធម៌នឹងបានទៅកើតក្នុងភពព្រហ្ម បើព្យាយាមធ្វើទាន រក្សាសីល ចំរើនសមាធិមានសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាន សន្សំបញ្ញាបារមីឱ្យច្រើននឹងបានសំរេចព្រះនិព្វាន តែទាំងសាសនាគ្រិស្តនិងឥស្លាម បញ្ជាក់ថាត្រូវតែជឿ ត្រូវតែមានជំនឿ គឺជឿទៅលើព្រះ ជឿទៅលើគម្ពីរ ហើយព្យាយាមបួងសួង សុំអង្វរករ សុំសេចក្ដីយល់ចិត្តមេត្តាប្រោសប្រណីអំពីព្រះទើបបានទៅនៅជាមួយព្រះ[3]។បើប្រៀបធៀបរវាងការធ្វើតបៈក្នុងសាសនាព្រាហ្មណ៍វិញ តើវិធីទាំងពីរនេះខុសគ្នាឬដូចគ្នាយ៉ាងណា? តើការបួងសួងអង្វរករអាចជួយនាំជីវិតយើងឱ្យជោគជ័យនិងសំរេចបានសេចក្ដីសុខបានពិតប្រាកដដែរឬទេ?។ ព្រះពុទ្ធសាសនាឈរនៅលើសេចក្ដីពិតនិងការបដិបត្តិដើម្បីឈានទៅរកជោគជ័យនិងការសំរេចបានសេចក្ដីសុខពិតប្រាកដ។

[2] Loving-kindness, compassion, sympathetic joy and equanimity.
[3] **a** (1) **:** belief and trust in and loyalty to God (2) **:** belief in the traditional doctrines of a religion **b** (1) **:** firm belief in something for which there is no proof (2) **:** complete trust.

*នហិ បព្វជិតោ អរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ* ប្រែថា “*ឈ្មោះថាបព្វជិតឬអ្នកបួស គឺមិនបៀតបៀន ធ្វើទុក្ខបុកម្នេញ និងសំលាប់សត្វដទៃឡើយ*” ត្រង់ចំណុចនេះជាការត្រាស់ចំពោះព្រះសង្ឃ ជាលក្ខណៈពិសេសចំពោះមនុស្សដែលជាគំរូគេ គឺមិនត្រូវបៀតបៀន សំលាប់អ្នកដទៃ ហើយមិនមែនធ្វើនាទីគ្រាន់តែជាមនុស្សដែលគេជឿថាអាចតភ្ជាប់រវាងមនុស្ស និងទេវតាឬព្រះអាទិទេពព្រះព្រហ្ម ដូចសាសនាមុនៗឬសាសនាមួយចំនួននៅសព្វថ្ងៃប៉ុណ្ណោះទេ[4] តែព្រះសង្ឃក្នុងព្រះពុទ្ធសាសនាបួសដើម្បីអប់រំខ្លួនឯង ហ្វឹកហាត់ខ្លួនឯង លាក់ខ្លួនបំពួនអាត្មាក្នុងទីស្ងាត់ មិនភ្លើតភ្លើនក្នុងទីជុំជនដែលពោរពេញទៅដោយរាគាទិកិលេស និងលោកីយសុខ។ ទាំងនេះជាគាថាទីមួយរបស់ព្រះសម្មាសម្ពុទ្ធនៅក្នុងមហាបទានសូត្រ ទីឃនិកាយ។

ចំណែកនៅក្នុងធម្មបទ ខុទ្ទកនិកាយ បែរជាសរសេរព្រះពុទ្ធវចនៈគាថានេះមុនគេ :

**សព្វបាបស្ស អករណំ          កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ          ឯតំ ពុទ្ធាន សាសនំ ។**

ដែលនេះអាចចាត់ទុកថា ជាខ្លឹមធម៌នៃពាក្យប្រៀនប្រដៅរបស់ព្រះអង្គបានដូចគ្នា។ *សព្វបាបស្ស អករណំ* ប្រែថា “ការមិនធ្វើនូវបាបទាំងពួង” (គឺមិនមែនប្រែថាចូរលះបង់នូវបាបទាំងពួងទេ) ដែលប្រការនេះគឺមិនធ្វើអកុសលកម្មបទ១០[៥] ជាដើម។ *កុសលស្សូបសម្បទា* ប្រែថា “ញុំាងកុសលឱ្យដល់ព្រម” គឺបំពេញ នូវកុសលកម្មបទ១០ ជាដើម។ *សចិត្តបរិយោទបនំ* ប្រែថា “ចូរធ្វើចិត្តឱ្យស្អាតផូរផង់” គឺបានដល់ការប្រឹង ប្រែងបដិបត្តិនូវសមាធិកម្មដ្ឋាន។ *ឯតំ ពុទ្ធាន សាសនំ* “នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ” ជាលក្ខណៈពិសេសមួយដែលពាក្យប្រៀនប្រដៅទាំងបីខាងលើនេះ គឺមានលក្ខណៈដូចគ្នាសំរាប់ព្រះពុទ្ធគ្រប់ ព្រះអង្គ ។

ក្រៅពីនេះនៅមានស្លោកដែលជាឱវាទបដិមោក្ខរបស់ព្រះពុទ្ធអង្គច្រើនទៀតដែលចាត់ទុកថាជាខ្លឹមធម៌របស់ព្រះពុទ្ធសាសនាដែរ តែសុំមិនលើកយកមកអធិប្បាយឱ្យលំអិតទាំងអស់នៅទីនេះ។

---

[4] one authorized to perform the sacred rites of a religion especially as a mediatory agent between humans and God; *specifically* **:** an Anglican, Eastern Orthodox, or Roman Catholic clergyman ranking below a bishop and above a deacon.

៥. កាយកម្ម៣ (សំលាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសផ្លូវកាម), វចីកម្ម៤ (និយាយកុហក់ និយាយញុះញង់គេ និយាយពាក្យអាសអាភាស និយាយពាក្យរោយរាយឥតប្រយោជន៍), មនោកម្ម៣ (សំលឹងឃើញតែចង់បានរបស់អ្នកដទៃ គិតព្យាបាទគុំនំគុំគួនអ្នកដទៃ មានមិច្ឆាទិដ្ឋិយល់ខុសពីសេចក្តីពិត)

ម្យ៉ាងវិញទៀតព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា *សព្វេ ធម្មា នាលំ អភិនិវេសាយ* ប្រែថា“ធម៌ទាំងឡាយទាំងពួងមិនគួរប្រកាន់ជ្រុល ឬប្រកាន់ថាជាតួខ្លួន តួអញ របស់អញ”។ ចំណុចនេះក៏ជាលក្ខណៈសំខាន់ដែលពុទ្ធសាសនិកជនមួយចំនួនយកមកអះអាងថា ជាខ្លឹមធម៌របស់ព្រះពុទ្ធសាសនា។

ចំណែកអ្នកផ្សេងទៀតក៏យកព្រះពុទ្ធវចនៈដែលថា “*ទាំងពេលមុននិងពេលឥឡូវនេះ តថាគតបង្រៀនធម៌តែ ម្យ៉ាងគឺទុក្ខហើយនិងការរលត់នូវទុក្ខ*” ដោយអះអាងថានេះក៏ជាខ្លឹមធម៌របស់ព្រះពុទ្ធសាសនាដែរ។

## បេះដូងតែមួយតែមានបួនបន្ទប់

ព្រះនាមរបស់ព្រះពុទ្ធអង្គមួយគឺ*សម្មាសម្ពុទ្ធោ* ឬដែលយើងទាំងអស់គ្នាស្គាល់យ៉ាងរត់មាត់គឺ ព្រះពុទ្ធ ព្រះពុទ្ធ ព្រះពុទ្ធ! ដែលប្រែថា “*ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចៈ ហើយទ្រង់ញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង*”។ ពុទ្ធបរិស័ទខ្មែរយើង ជាពិសេសយុវជនខ្មែរជំនាន់ក្រោយភាគច្រើននៅមិនទាន់ស្គាល់ព្រះពុទ្ធច្បាស់នៅឡើយ បើមានសំណួរថាតើព្រះពុទ្ធជានរណា?ពួកគេអាចមានការស្រម៉ៃថាព្រះពុទ្ធគឺរូបបដិមាករដែលដាក់តាំងនៅតាមវត្តវាអារាមពាសពេញព្រះរាជាណាចក្រកម្ពុជា។ ដែលខុសពីពួកអ៊ឺរ៉ុប ជាពិសេសយុវជនអាមេរិកាំង ដែលស្គាល់ព្រះពុទ្ធយ៉ាងច្បាស់ថា **“ជាអ្នកត្រាស់ដឹង”**(awaken one or enlightened one) ត្រាស់ដឹងនូវអ្វី? គឺត្រាស់ដឹងនូវអរិយសច្ច៤(four noble truth) ដែលអរិយសច្ច៤នេះអាចចាត់ទុកថាជាខ្លឹមធម៌ឬជាបេះដូងរបស់ព្រះពុទ្ធសាសនា។

នៅក្នុងឱវាទបដិមោក្ខដូចដែលបានពោលមកគឺ *ខន្តីគឺជាតបៈដ៏ឧត្តម ព្រះនិព្វានគឺបរមធម៌* អាចគិតយ៉ាងសាមញ្ញថា ការអត់ធន់ចំពោះសេចក្តីទុក្ខឬហៅថាតបៈអាចរួមចូលជាអរិយសច្ចទី១បាន គឺទុក្ខអរិយសច្ចដែលព្រះអង្គបង្រៀនថាឱ្យយើងកំណត់ដឹង មានសេចក្តីអត់ធន់កំណត់ដឹងចំពោះសេចក្តីទុក្ខនោះ។ ព្រះនិព្វានគឺជាបរមធម៌ក៏ជាអរិយសច្ចទី៣ គឺនិរោធអរិយសច្ច ដែលជាបរមសុខគឺព្រះនិព្វាន។ ចំណែក*ការមិនធ្វើនូវបាបទាំងពួង ញ៉ាំងកុសលឱ្យពេញបរិបូរ និងធ្វើចិត្តឱ្យបរិសុទ្ធិ* ព្រះអដ្ឋកថាចារ្យ ចាត់ទុកថាជា*សីល សមាធិ បញ្ញា*។ ការមិនធ្វើនូវបាបទាំងពួងគឺសីល ការញ៉ាំងកុសលឱ្យពេញបរិបូរគឺសមាធិ និងធ្វើចិត្តឱ្យស្អាតផូរផង់គឺបញ្ញា។ សីល សមាធិ បញ្ញា នេះជាផ្នែកមួយរបស់អរិយសច្ចទី៤ គឺអរិយគាមិនីបដិបទាអរិយសច្ចប្រកបដោយអង្គ៨ គឺសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ចាត់ទុកថាសីល, សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ចាត់ទុកថាសមាធិ និង សម្មាទិដ្ឋិ សម្មាសង្កប្បៈ ចាត់ទុកថាជាបញ្ញា។

ចំណែកធម៌ទាំងឡាយមិនគួរចូលប្រកាន់ជ្រុលឬប្រកាន់ថាជាតួអញ របស់អញ ក៏អាចចាត់ទុកថាមានភាពរួមជាមួយអរិយសច្ច៤បាន ដូចជាព្រះអង្គសំដែងចំពោះតែហេតុនិងផលនៅក្នុងអរិយសច្ច។ ទុក្ខសច្ចៈជា *បរិញ្ញេយ្យកិច្ច*គឺកំណត់ដឹង (ផល) សមុទយសច្ចៈ ជា*បហាតព្វកិច្ច* គឺត្រូវលះបង់ចោលឱ្យអស់ (ហេតុ)។ និរោធសច្ចៈ ជា*សច្ឆិកាតព្វកិច្ច* (ផល) និងមគ្គសច្ចៈ ជា*ភាវេតព្វកិច្ច* (ហេតុ)។ ដូច្នេះ ធម៌អរិយសច្ចបួននេះគ្រាន់តែជាហេតុនិងផលរវាងគ្នានឹងគ្នា ព្រមទាំងបំពេញកិច្ចទាំងឡាយឱ្យបានពេញបរិបូរ ដោយសំខាន់មិនចាំបាច់ចូលទៅជំពាក់ជំពិន ប្រកាន់ខ្ជាប់ ឬសំគាល់ថាខ្លួនអញ តួអញ និងរបស់អញឡើយ។

ជាក់ស្តែងពុទ្ធវចនៈដែលថា *តាំងពីមុនមករហូតដល់ឥឡូវនេះ តថាគតសំដែងពីសេចក្តីទុក្ខនិងការរំលត់នូវទុក្ខ* គឺមានន័យថាព្រះអង្គសំដែងចំពោះទុក្ខសច្ចៈនិងនិរោធសច្ចៈ តែយ៉ាងណាក៏ដោយនៅពេលសំដែងពីទុក្ខគឺផល ដោយធម្មជាតិនៃធម៌គឺត្រូវមានហេតុរបស់វាគឺសមុទយសច្ចៈ ដូចគ្នាដែរនៅពេលព្រះអង្គសំដែងពីការរលត់នូវទុក្ខគឺនិរោធសច្ចៈ ដែលជាផល ដោយធម្មជាតិនៃធម៌គឺត្រូវមានហេតុរបស់វាគឺអរិយមគ្គប្រកបដោយអង្គ៨នោះឯង។ ធម៌ដែលសំខាន់ផ្សេងទៀតដូចជា*បដិច្ចសមុប្បាទៈ* ក៏អាចសង្គ្រោះចូលជាអរិយសច្ច៤នេះបានទាំងអស់។

ដូច្នេះអរិយសច្ច៤ ចាត់ទុកថាជាប្រជុំនៃធម៌របស់ព្រះសម្មាសម្ពុទ្ធទាំងអស់ ជាពិសេសធម៌ទាំង ៨៤០០០ ព្រះធម្មក្ខន្ធ ឬក៏ធម៌ដែលព្រះអង្គត្រាស់ដឹងទាំងអស់មករួមបញ្ចូលនៅក្នុងអរិយសច្ច៤ នេះឯង។ ជាចុងក្រោយយើងអាចយល់យ៉ាងទូលំទូលាយនិងច្បាស់លាស់ថា ខ្លឹមធម៌របស់ព្រះពុទ្ធសាសនា ច្បាស់ជាមកប្រជុំគ្នាក្នុងអរិយសច្ច៤នេះ ហើយអរិយសច្ច៤នេះឯងគឺជាខ្លឹមធម៌របស់ព្រះពុទ្ធសាសនា។

សព្វថ្ងៃនេះទង្វើគ្រប់យ៉ាងរបស់មនុស្សមិនអាចគេចចេញផុតពីអរិយសច្ច៤នេះបានឡើយ ជាក់ស្តែងពួកអ្នកវិទ្យាសាស្ត្រ អ្នកត្រួតពិនិត្យជំងឺ អ្នកជំនួញ(business man) អ្នកសេដ្ឋសាស្ត្រ(economists) អ្នកនយោបាយ(politicians) និងអ្នកសង្គមសាស្ត្រ(sociologists) ជាដើម ។

